# ព័ត៌មានលម្អិតស្ដីអំពី ថ្នាំប្យីព្រេណ័រហ្វីន

The Facts about Buprenorphine for Treatment of Opioid Addiction



## សម្រាប់ព្យាបាលការញៀនអាភៀន

Substance Abuse and Mental Health Services Administration
SAMHSA
www.samhsa.gov • 1-877-SAMHSA-7 (1-877-726-4727)

*This brochure provides basic information about the use of buprenorphine in medication-assisted treatment for opioid addiction. It describes how buprenorphine works, the proper use of the medication, and common side effects. It also explains how buprenorphine fits into the overall recovery process. The brochure is directed at patients entering medication-assisted treatment for opioid addiction, and it may be useful to patients' family members and friends. To view the English version, please visit http://store.samhsa.gov/product/The-Facts-about-Buprenorphine-for-Treatment-of-Opioid-Addiction/SMA15-4442.*

*“ខ្ញុំធ្លាប់ត្រូវគេបាញ់នៅតាមផ្លូវ។ ខ្ញុំធ្លាប់រស់នៅក្នុងមជ្ឈមណ្ឌលផ្ដាច់ថ្នាំញៀន។ នៅទីនោះគឺជាគុក...។ ខ្ញុំដឹងថាការស្លាប់ជិតនឹងកើតឡើងចំពោះខ្ញុំ... ដូច្នេះខ្ញុំក៏ចាប់ផ្ដើមការព្យាបាលផ្ដាច់ថ្នាំញៀន...។ អស់រយៈពេល 15 ឆ្នាំកន្លងមកហើយ ជីវិតរបស់ខ្ញុំមិនដែលបានល្អប្រសើរឡើយ។”*

*តុលា*

តើអ្នកអាចគេចផុតពីទុក្ខវេទនា និងគ្រោះថ្នាក់នៃការញៀនថ្នាំតាមរបៀបណា? មនុស្សភាគច្រើនមិនអាចផ្ដាច់រោគញៀនថ្នាំបានដោយខ្លួនឯងឡើយ។ ពួកគេត្រូវការជំនួយ ដើម្បីត្រឡប់ទៅរកការរស់នៅជាធម្មតាប្រកបដោយសុខភាពល្អឡើងវិញ។ ជំនួយដែលសំខាន់បំផុតនោះគឺការព្យាបាលដោយប្រើថ្នាំ។

មានវិធី 3 យ៉ាងដែលមានសារៈសំខាន់ដូចគ្នានៅក្នុងការព្យាបាលនេះ៖

- ការប្រើថ្នាំ
- ការប្រឹក្សាយោបល់
- ការគាំទ្រពីគ្រួសារ និងមិត្តភក្តិ។

**ថ្នាំប៊្យុព្រណ័រហ្វីន (buprenorphine)** គឺជាថ្នាំមួយប្រភេទដែលប្រើប្រាស់សម្រាប់ព្យាបាលការញៀនអាភៀន។ ប្រហែលជាវេជ្ជបណ្ឌិតរបស់អ្នក និងអ្នកផ្ដល់សេវាខាងព្យាបាលគ្រឿងញៀនបានណែនាំអ្នករួចមកហើយ ឬប្រហែលអ្នកបានប្រើថ្នាំនេះហើយ។ កូនសៀវភៅនេះនឹងផ្ដល់ដល់លោកអ្នកនូវព័ត៌មានពិតដែលអ្នកត្រូវដឹង។

ចំណាំ៖ ពាក្យសំខាន់ៗដែលប្រើជាញឹកញាប់ក្នុងការព្យាបាលនៅក្នុងសៀវភៅនេះនឹងសរសេរជា **អក្សរដិតខ្មៅ**។

## *ការញៀនអាភៀនគឺជាជំងឺមួយ។*

អាភៀនគឺជាថ្នាំដែលធ្វើឲ្យរាងកាយមានចលនាយឺតយ៉ាវ ដូចជាការដកដង្ហើម និងចង្វាក់បេះដូង។ អាភៀនថែមទាំងប៉ះពាល់ដល់ខួរក្បាល ហើយអាចបង្កើនអារម្មណ៍ឲ្យរីករាយផងដែរ។ អាភៀនជាថ្នាំដែលធ្វើចេញពីដើមអាភៀន។

គ្រូពេទ្យចេញវេជ្ជបញ្ជាថ្នាំអាភៀន ដើម្បីព្យាបាលការឈឺចុកចាប់ ហើយពេលខ្លះដើម្បីព្យាបាលជំងឺដទៃទៀត ដូចជា ជំងឺក្អកធ្ងន់ធ្ងរ។ ហេរ៉ូអ៊ីន គឺជាថ្នាំអាភៀនខុសច្បាប់មួយដែលមនុស្សជក់ ហិត ឬ ចាក់ដើម្បីឲ្យមានអារម្មណ៍ល្អដែលជាញឹកញាប់ហៅថា "ថ្នាំធ្វើឲ្យរំជើបរំជួល" ឬ "ថ្នាំបន្ទាន់"។ ពេលខ្លះ មនុស្សក៏ស្វែងរកអារម្មណ៍រីករាយ ដោយប្រើថ្នាំអាភៀនក្នុងបរិមាណច្រើន ដែលគ្រូពេទ្យបានចេញជាវេជ្ជបញ្ជាឲ្យមកខ្លួន។

ប្រសិនបើអ្នកប្រើប្រាស់អាភៀន អ្នកអាចស៊ាំនឹងវា។ នេះមានន័យថាអ្នកត្រូវការថ្នាំក្នុងបរិមាណច្រើនថែមទៀត ដើម្បីទទួលបាននូវប្រសិទ្ធិភាពរបស់វា។ អ្នកប្រហែលអាចទៅជាត្រូវការចាំបាច់នូវអាភៀនផងដែរ។ នេះមានន័យថា ប្រសិនបើអ្នកឈប់ប្រើអាភៀនអ្នកនឹងមានការឈឺ។ ការឈឺនេះហៅ**ថាការដកខ្លួនឈប់ប្រើ**។ ការត្រូវការជាចាំបាច់មិនមានអត្ថន័យដូចគ្នានឹង**ការញៀន**នោះទេ ប៉ុន្តែពេលខ្លះការត្រូវការជាចាំបាច់នេះបណ្តាលទៅជា**ការញៀន**។ សញ្ញាបង្ហាញពី**ការញៀន**មានដូចជា៖

- **ចំណង់ដ៏ខ្លាំង** – ចិត្តបង្កើតឲ្យមានអារម្មណ៍ចង់ប្រើថ្នាំញៀនខ្លាំង។
- **បាត់បង់ការគ្រប់គ្រង** – កាន់តែពិបាកទ្រាំពេលគ្មានថ្នាំញៀនប្រើ។ ចាំបាច់ត្រូវប្រើ និងប្រើបន្ត ទោះបីជាថ្នាំញៀនបង្កមហន្តរាយក៏ដោយ។

ភាពស៊ាំ និងការត្រូវការជាចាំបាច់ ជាឥទ្ធិពលធម្មតាដែលកើតមកពីការប្រើប្រាស់ថ្នាំអាភៀនតាមវេជ្ជបញ្ជាដែលអាចគ្រប់គ្រងបាន ក្រោមការថែទាំរបស់វេជ្ជបណ្ឌិត។ ភាពស៊ាំ និងការត្រូវការជាចាំបាច់ ក៏ជាផលប៉ះពាល់បណ្តាលមកពីការប្រើថ្នាំអាភៀនដែលមិនត្រឹមត្រូវផងដែរ។ ការញៀនមិនទំនងកើតមានចំពោះបុគ្គលដែលប្រើប្រាស់ថ្នាំបានត្រឹមត្រូវនោះទេ ប៉ុន្តែពេលខ្លះករណីនេះអាចកើតមាន។ ជាធម្មតា ការញៀនកើតឡើងដោយសារការប្រើប្រាស់ថ្នាំមិនបានត្រឹមត្រូវ។ មនុស្សខ្លះមានការប្រឈមមុខនឹងគ្រោះថ្នាក់នៃការញៀនថ្នាំរឹតតែខ្លាំង ដោយសារជីន (ពូជ) ផ្លូវអារម្មណ៍ ឬស្ថានការណ៍ផ្ទាល់ខ្លួន។

មិនមែនមនុស្សគ្រប់ៗគ្នា ដែលប្រើប្រាស់ថ្នាំអាភៀន ក្លាយជាញៀនថ្នាំនោះទេ។ ប៉ុន្តែ ជាការពិបាកក្នុងការឈប់ប្រើថ្នាំអាភៀន បន្ទាប់ពីអ្នកញៀនថ្នាំរួចហើយ ពីព្រោះចំណង់ចង់ប្រើថ្នាំគឺខ្លាំង ហើយការភ័យខ្លាចនៃការដកខ្លួនឈប់ប្រើ ក៏មានកម្រិតខ្លាំងដែរ។

## *ការញៀនអាភៀនអាចព្យាបាលបាន។*

ការញៀនអាភៀនគឺជា**ជំងឺរ៉ាំរ៉ៃ**មួយ ដូចជំងឺបេះដូង ឬជំងឺទឹកនោមផ្អែម។ **ជំងឺរ៉ាំរ៉ៃ**គឺជាបញ្ហាសុខភាពសម្រាប់ជីវិត។ វាមិនអាចព្យាបាលបានទេ ប៉ុន្តែអាចគ្រប់គ្រងបាន។ មនុស្សដែលមានការញៀនថ្នាំអាចមានសុខភាពល្អឡើងវិញ និងមានជីវិតរីកចំរើនឡើងវិញបាន។

ប៉ុន្តែប្រសិនបើអ្នកដូចមនុស្សភាគច្រើន អ្នកមិនអាចផ្តាច់ពីការញៀនបានដោយខ្លួនឯងឡើយ។ ជាការ**ព្យាបាល** – ដែលការថែទាំរបស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងអ្នកផ្តល់សេវាក្នុងការព្យា**លបាល**គ្រឿងញៀន – អាចជួយលោកអ្នកបាន។

ការព្យាបាលអាចជួយអ្នកឲ្យបោះបង់បញ្ហាញៀនថ្នាំ។ វាអាចជួយអ្នកឲ្យរួចពីការដកខ្លួនឈប់ប្រើ និងអាចទប់ទល់នឹងចំណង់ប្រើថ្នាំខ្លាំង។ ការព្យាបាលក៏អាចជួយអ្នកឲ្យផ្លាស់ប្តូរនូវគំនិតនៃការញៀនថ្នាំ ទៅជាឈប់មានលំអោនប្រកបដោយសុខភាពល្អ។ វាក៏អាចជួយឲ្យអ្នកបោះបង់នូវឥរិយាបទដែលប្រកបដោយគ្រោះថ្នាក់ផ្សេងៗទៀត ដូចជាការផឹកស្រា ឬ ការប្រើប្រាស់ថ្នាំញៀនប្រភេទផ្សេងទៀត ក្រៅអំពីបញ្ហាញៀនអាភៀន។

ជាការសំខាន់ដូចគ្នាដែរ ការព្យាបាលអាចជួយអ្នកដោះស្រាយបញ្ហាជីវិត ដែលអាចមានដែលជាប់ពាក់ព័ន្ធទៅនឹងការញៀន ដូចជាមានអារម្មណ៍ថាខ្លួនឯងមានតម្លៃទាប ស្ថានការណ៍អាក្រក់ណាមួយនៅកន្លែងធ្វើការ ឬនៅផ្ទះ ឬការចំណាយពេលវេលាជាមួយអ្នកប្រើថ្នាំញៀន។ បើនិយាយឲ្យខ្លី ការព្យាបាលនឹងជួយអ្នកឲ្យវិលត្រឡប់ទៅរករបៀបរស់នៅដែលឈប់មានការញៀន និងប្រកបដោយសុខភាពល្អ – ទៅរករបៀបរស់នៅមួយ ដែលគេហៅថា ដំ**ណើរជាសះស្បើយឡើងវិញ**។

## *ការព្យាបាលអាចរួមទាំងការប្រើថ្នាំ។*

**ការព្យាបាលដោយប្រើថ្នាំជាជំនួយ** ជាការព្យាបាលនៃការញៀនដែលរួមមាន ការប្រើថ្នាំ ព្រមជាមួយការផ្តល់ប្រឹក្សាយោបល់ និងការគាំទ្រដទៃផ្សេងទៀត។ ជាញឹកញាប់ ការព្យាបាលដោយប្រើថ្នាំ ជាជម្រើសដ៏ល្អប្រសើរបំផុតក្នុងការព្យាបាលការញៀនអាភៀន។

បើអ្នកញៀន ថ្នាំអាចធ្វើឲ្យអ្នកមានសុខភាពផ្លូវចិត្តជាធម្មតាឡើងវិញ រួចផុតពីផ្លូវអារម្មណ៍រំជើបខ្លាំង ឬខ្សោយដែលជំរុញដោយថ្នាំញៀន។ ថ្នាំអាចជួយអ្នកមិនឲ្យគិតពីថ្នាំញៀនគ្រប់ពេលវេលា។ ថ្នាំអាចបន្ធូរបន្ថយនូវការដកខ្លួនឈប់ប្រើ និងចំណង់ចង់ប្រើដ៏ខ្លាំង។ ការផ្លាស់ប្តូរទាំងនេះអាចផ្តល់ឱកាសដល់អ្នកឲ្យផ្តោតទៅលើការផ្លាស់ប្តូរក្នុងជីវិតរស់នៅដែលនាំទៅរកជីវិតដែលមានសុខភាពល្អឡើងវិញ។



ការប្រើថ្នាំសម្រាប់ការព្យាបាលការញៀនអាភៀន គឺដូចជាការប្រើថ្នាំសម្រាប់គ្រប់គ្រងជំងឺបេះដូង និង ទឹកនោមផ្អែមដែរ។ វាមិនមែនដូចជាការជំនួសថ្នាំញៀនណាមួយ ដោយថ្នាំញៀនមួយប្រភេទទៀតឡើយ។ បើប្រើប្រាស់ត្រឹមត្រូវ ថ្នាំមិនបង្កឲ្យមានការញៀនថ្មីឡើយ។ វាអាចជួយអ្នកគ្រប់គ្រងការញៀនរបស់អ្នក ដូច្នេះអាចរក្សាផលប្រយោជន៍ក្នុងការជាសះស្បើយបាន។

## *ថ្នាំប៊្យូព្រេណរ័ហ្វីន (buprenorphine) ជាថ្នាំមួយប្រភេទដែលគេប្រើដើម្បីព្យាបាលការញៀនអាភៀន។*

**ថ្នាំប៊្យូព្រេណរ័ហ្វីន (buprenorphine)** ជាថ្នាំមួយក្នុងចំណោមថ្នាំបីប្រភេទដែលប្រើញឹកញាប់ក្នុងការព្យាបាលការញៀនអាភៀន។ ថ្នាំពីរប្រភេទទៀតគឺ **មេតាដូន (methadone)** និង **ណាល់ត្រិកហ្សូន (naltrexone)**។ តម្លៃមានខុសៗគ្នា សម្រាប់ប្រភេទថ្នាំផ្សេងៗគ្នា។ អ្នកត្រូវពិចារណាលើបញ្ហានេះ ពេលអ្នកគិតគូរពីការព្យាបាលរបស់អ្នក។

អ្នកដែលប្រើថ្នាំ buprenorphine មានអារម្មណ៍ជាធម្មតាគ្មានការរំជើបរំជួលខ្លាំងនោះទេ។ ក៏ប៉ុន្តែខួរក្បាលគិតថាវាកំពុងទទួលសារជាតិអាភៀន ដូច្នេះសញ្ញានៃការដកថយ ឬការឈឺក៏មិនមានឡើយ។ ថ្នាំ buprenorphine ថែមទាំងកាត់បន្ថយនូវចំណង់ប្រើខ្លាំងផងដែរ។ បើចំណង់ចង់ប្រើខ្លាំងបន្តនៅជាបញ្ហា វេជ្ជបណ្ឌិតរបស់អ្នកនឹងកែប្រែថ្នាំព្យាបាលរបស់អ្នក ឬជួយអ្នករកវិធីសាស្ត្រផ្សេងទៀតដើម្បីកាត់បន្ថយនូវអារម្មណ៍នោះ។

អ្នកបៀមគ្រាប់ថ្នាំ buprenorphine ឲ្យវារលាយក្រោមអណ្តាត។ អ្នកមិនត្រូវទំពារ ឬលេបឡើយ។ ថ្នាំនេះមានជាពីរបែប។ **ថ្នាំស៊ាប់ប៊ូហ្សូន (Suboxone®)** មានសារធាតុ buprenorphine ព្រមជាមួយនឹងថ្នាំមួយទៀតដែល **ហៅថាណាឡូហ្សូន (naloxone)**។ ណាឡូហ្សូនត្រូវបានយកមកដាក់បន្ថែមដើម្បីការពារការប្រើប្រាស់ហួសកម្រិត – សារធាតុនេះធ្វើឲ្យមានការដកខ្លួនឈប់ប្រើដល់មនុស្សណាដែលញៀនដោយប្រើប្រាស់ buprenorphine ហួសកម្រិតដោយចាក់ចូលសាច់។ **ថ្នាំស៊ូប៊ូតិច (Subutex®)** មានតែសារធាតុ buprenorphine ប៉ុណ្ណោះ។ វេជ្ជបណ្ឌិតចេញថ្នាំប្រភេទនេះ ប្រសិនបើអ្នកមិនប្រើប្រាស់ណាឡូហ្សូន ដោយសារមូលហេតុណាមួយដូចជា ប្រសិនបើអ្នកមានប្រតិកម្មទៅនឹងថ្នាំ ឬអ្នកមានផ្ទៃពោះ។

ថ្នាំនេះត្រូវលេបមួយគ្រាប់ក្នុងមួយថ្ងៃ។ រយៈពេលយូរថ្ងៃទៅ គម្លាតនៃការប្រើថ្នាំនេះអាចបន្តប្រើមួយគ្រាប់ក្នុងមួយថ្ងៃ ឬ អាចបន្ថយមកត្រឹមមួយគ្រាប់ 2 ថ្ងៃម្តង។

សារៈប្រយោជន៍ចំបងនៃការប្រើថ្នាំ buprenorphine មាន៖

- អ្នកនឹងមិនអាចប្រើថ្នាំ buprenorphine ហួសកម្រិតទេ ប្រសិនបើអ្នកប្រើត្រឹមត្រូវ។
- ថ្នាំ buprenorphine មានប្រសិទ្ធភាពរយៈពេលយូរ។ នេះមានន័យថា បន្ទាប់ពីការប្រើលើកដំបូងមក វេជ្ជបណ្ឌិតរបស់អ្នកអាចឲ្យអ្នកប្រើវារៀងរាល់ 2 ថ្ងៃម្តង ជាជាងប្រើមួយថ្ងៃម្តង។
- វេជ្ជបណ្ឌិតអាចចេញវេជ្ជបញ្ជាថ្នាំ buprenorphine ដូច្នេះអ្នកអាចប្រើវានៅផ្ទះ។ **ការសំខាន់៖** មិនមែនគ្រូពេទ្យទាំងអស់អនុម័តឲ្យចេញវេជ្ជបញ្ជាលើថ្នាំនេះទេ ហើយមិនមែនគ្រូពេទ្យទាំងអស់ផ្តល់ការប្រឹក្សាយោបល់លើគ្រឿងញៀនទេ។ ការមកព្យាបាលប្រចាំថ្ងៃនៅមជ្ឈមណ្ឌលព្យាបាលអាចជួយក្នុងការជាសះស្បើយ។ ដូច្នេះ សម្រាប់មនុស្សខ្លះ មណ្ឌលព្យាបាលគឺជាកន្លែងដ៏ល្អបំផុត ដើម្បីទទួលយកថ្នាំសម្រាប់ការញៀនអាភៀន។

## *វេជ្ជបណ្ឌិតអាចចេញវេជ្ជបញ្ជាថ្នាំ buprenorphine ប្រសិនបើថ្នាំនេះជាជំរើសត្រឹមត្រូវសម្រាប់អ្នក។*

នៅមុនពេលអ្នកទទួលបានថ្នាំព្យាបាលលើកទីមួយសម្រាប់ព្យាបាលការញៀនអាភៀន វេជ្ជបណ្ឌិតនឹងសួរ
សំណួរអ្នកអំពីការញៀនថ្នាំ សុខភាព និងបញ្ហាដទៃទៀត។ អ្នកទទួលបានការធ្វើតេស្តពិនិត្យថ្នាំ ដែលជា
ធម្មតាគឺពិនិត្យទឹកនោម ឬទឹកមាត់។ អ្នកថែមទាំងទទួលការពិនិត្យផ្នែករាង្គកាយ និងពិនិត្យជំងឺផ្សេងៗទៀត
ផងដែរ ដែលជាជំងឺកើតឡើងជាធម្មតាចំពោះអ្នកដែលប្រើប្រាស់ថ្នាំញៀន។ នឹងមានការពិនិត្យមើលថ្លើមរបស់
អ្នក ដើម្បីឲ្យដឹងច្បាស់ថាអ្នកអាចប្រើថ្នាំនោះប្រកបដោយសុវត្ថិភាពផងដែរ។ ប្រសិនបើថ្នាំ buprenorphine
មានសុវត្ថិភាពនឹងសមស្របចំពោះអ្នក វេជ្ជបណ្ឌិតអាចណែនាំថ្នាំនេះ។

អ្នក និងវេជ្ជបណ្ឌិតរបស់អ្នក ឬអ្នកផ្តល់សេវាព្យាបាលគ្រឿងញៀនធ្វើការសម្រេចចិត្តរួមគ្នាលើផែនការ
សម្រាប់ការព្យាបាល។ ផែនការនឹងពណ៌នាពីការព្យាបាលដោយថ្នាំជាប្រចាំ ការប្រឹក្សាយោបល់ និងសេវា
ផ្សេងៗទៀតដែលនឹងត្រូវបានផ្តល់ឲ្យ និងវិន័យដែលត្រូវអនុវត្តតាម។ វិន័យនេះនឹងត្រូវបានពន្យល់ជូន
អ្នក ហើយអ្នកនឹងទទួលបានឯកសារពីវិន័យនេះជាលាយលក្ខណ៍អក្សរ។

## *Buprenorphine ត្រូវតែប្រើប្រាស់ដោយប្រុងប្រយ័ត្ន។*

វេជ្ជបណ្ឌិតរបស់អ្នកនឹងចេញវេជ្ជបញ្ជាថ្នាំកម្រិតទាប ដើម្បីចាប់ផ្តើមប្រើនៅពេលចាប់ធ្វើទុក្ខក្រោយពេលឈប់
ប្រើគ្រឿងញៀន។ កម្រិតថ្នាំអាចផ្លាស់ប្តូរតាមការចាំបាច់។ សូមប្រើថ្នាំតាមការចេញវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត
អ្នកជានិច្ច។

ដំបូង ថ្នាំ buprenorphine អាចធ្វើឲ្យអ្នកងងុយ ឬស្រវឹង។ អ្នកមិនត្រូវបើកបរឡាន ឬធ្វើការងារណា
ផ្សេងទៀតដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំង លុះត្រាអ្នកដឹងថាតើថ្នាំនេះធ្វើទុក្ខប៉ះពាល់ដល់អ្នកយ៉ាង
ដូចម្តេច។ បើភាពងងុយគេងនៅតែបន្តជាបញ្ហា វេជ្ជបណ្ឌិតរបស់អ្នកប្រហែលជានឹងផ្លាស់ប្តូរកម្រិតថ្នាំ។

អ្នកអាចប្រើថ្នាំ buprenorphine រយៈពេលច្រើនថ្ងៃ ច្រើនខែ ឬ ច្រើនឆ្នាំ - ទៅតាមការចាំបាច់សម្រាប់កាពារ
ជំងឺលាប់មកវិញ។ ក៏ប៉ុន្តែ អ្នកត្រូវឲ្យវេជ្ជបណ្ឌិតពិនិត្យឲ្យបានញឹកញាប់ បើអ្នកមានជំងឺថ្លើម។

បើអ្នកមានស្ថេរភាពក្នុងដំណើរជាសះស្បើយឡើងវិញ ហើយចង់ឈប់ប្រើថ្នាំ  buprenorphine អ្នកត្រូវ
បញ្ឈប់ដោយយឺតៗ ក្នុងរយៈពេលមួយ។ មធ្យោបាយនេះហៅថា **ការកាត់បន្ថយបន្តិចម្តងៗ។ ការកាត់បន្ថយ
បន្តិចម្តងៗ** មានប្រសិទ្ធិភាពបំផុត ប្រសិនបើមានជំនួយពីវេជ្ជបណ្ឌិតរបស់អ្នក ឬពីអ្នកផ្តល់សេវាព្យាបាល
គ្រឿងញៀន បន្ទាប់ពីការព្យាបាលមានការរីកចំរើន។

## ការរំលឹក

- ពេលកំពុងប្រើថ្នាំនេះ អ្នកមិនត្រូវប្រើថ្នាំអ្វីផ្សេងទៀតដោយគ្មានការប្រឹក្សាយោបល់ជាមួយវេជ្ជបណ្ឌិតរបស់អ្នកជាមុនឡើយ។
- ពេលកំពុងប្រើថ្នាំនេះ អ្នកមិនត្រូវប្រើថ្នាំអ្វីដែលខុសច្បាប់ ទទួលទានជាតិអាកុល ឬថ្នាំធ្វើឲ្យសន្លប់ ឬថ្នាំណាដែលនាំឲ្យពិបាកដកដង្ហើម។ ការប្រើថ្នាំទាំងឡាយច្រើនហួសពេក ព្រមទាំងថ្នាំ buprenorphine ផង អាចនាំឲ្យលើសចំនួន ឬស្លាប់ថែមទៀត។
- ថ្នាំ buprenorphine ដែលទុកនៅផ្ទះ **ត្រូវ**តែចាក់សោនៅក្នុងកន្លែងដែលមានសុវត្ថិភាពដើម្បីការពារកុំឲ្យអ្នកផ្សេងទៀតច្រឡំប្រើដោយចៃដន្យ ជាពិសេសកូនក្មេង។
- បើអ្នកជាស្ត្រីកំពុងមានផ្ទៃពោះ ឬបំបៅកូនដោយទឹកដោះម្តាយ ថ្នាំមេតាដូន (methadone) គឺមានសុវត្ថិភាពជាង buprenorphine សម្រាប់ម្តាយនិងកូន។ ក្នុងកាលៈទេសៈពិសេស វេជ្ជបណ្ឌិតអាចសំណូមពរឲ្យប្រើថ្នាំណាឡុហ្សូន (naloxone) – ថ្នាំដែលគ្មានជាតិ buprenorphine ជំនួសថ្នាំមេតាដូន (methadone)។ សូមសួរវេជ្ជបណ្ឌិតរបស់អ្នកសម្រាប់ព័ត៌មានបន្ថែមទៀត។
- បញ្ហាថ្លើមមិនសូវមានទេ ប៉ុន្តែអាចកើតមានឡើង។ ប្រសិនបើអ្នកមានជំងឺថ្លើមពីមុនសម្រាប់វេជ្ជបណ្ឌិតរបស់អ្នកគួរធ្វើតេស្តពិនិត្យថ្លើមរបស់អ្នកឲ្យបានទៀងទាត់។

### *ថ្នាំ Buprenorphine មានឥទ្ធិពលកើតមានឡើងចំពោះមនុស្សខ្លះ។*

ឥទ្ធិពលដែលអាចកើតមានឡើង គឺជា**អារម្មណ៍មិនស្រួលក្នុងខ្លួន** ឬ**អាការៈឈឺ**ដែលបណ្តាលមកពីការប្រើថ្នាំ។ ថ្នាំ buprenorphine មានឥទ្ធិពលកំរិតមធ្យមបន្តិចបន្តួច។ ជាធម្មតាវានឹងបាត់ទៅវិញបន្ទាប់ពីបានប្រើថ្នាំមួយរយៈមក។

បើអ្នកជួបប្រទះឥទ្ធិពលដែលអាចកើតឡើង អ្នកមិនត្រូវឈប់ប្រើថ្នាំនេះឡើយ។ ផ្ទុយទៅវិញ អ្នកត្រូវនិយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នក ឬអ្នកផ្តល់សេវាព្យាបាលគ្រឿងញៀន។ ការផ្លាស់ប្តូរកម្រិតថ្នាំ ឬការផ្លាស់ប្តូរប្រភេទថ្នាំអាចជួយអ្នកបាន។ មានវិធីស្រួលខ្លះៗដែលអ្នកអាចធ្វើបានដើម្បីកាត់បន្ថយនូវឥទ្ធិពលដែលកើតនេះផងដែរ។

## ឥទ្ធិពលដែលកើតឡើងជាទូទៅ និង វិធីស្រួលៗ ដើម្បីកាត់បន្ថយឥទ្ធិពលនេះ

**ឈឺខ្លួន ឈឺក្បាល និង ផ្តាសាយ - ឬ រោគសញ្ញាដូចគ្រុន** - សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកពីថ្នាំដែលអ្នកអាចប្រើពេលទិញមកពីទីផ្សារ។

**វិលមុខ** - ងើបឈរឡើងយឺតៗ។ ទូរស័ព្ទទៅកាន់វេជ្ជបណ្ឌិតរបស់អ្នក បើបញ្ហានៅតែបន្ត។

**ទល់លាមក** - ផឹកទឹកឲ្យច្រើនជាងទឹកផ្លែឈើ។ ញ៉ាំម្ហូបអាហារដែលមានជាតិសរសៃ (fiber)។ ហាត់ប្រាណឲ្យបានច្រើន។

**បែកញើស** - ងូតទឹកឲ្យបានញឹកញាប់។ ពាក់សម្លៀកបំពាក់ច្រើនជាន់។

**បញ្ហាគេងដោយរួមទាំងភាពអស់កម្លាំង** - លេបថ្នាំនៅពេលព្រឹក។ សូមកុំគេងពេលថ្ងៃ។ ចូលគេងនៅម៉ោងដដែលរៀងរាល់យប់។ ត្រូវហាត់ប្រាណ។ កុំញ៉ាំភេសជ្ជៈដែលមានជាតិកាហ្វេ ក្រោយពេលបាយថ្ងៃត្រង់។

**ឈឺក្រពះ ឬក្អួត** - លេបថ្នាំក្រោយពេលញ៉ាំអាហារ។ បន្ទាប់មកលេបថ្នាំក្រពះ តាមការណែនាំរបស់គ្រូពេទ្យអ្នក។

**អារម្មណ៍ប្រែប្រួល** - ហាត់ប្រាណឲ្យបានច្រើន។ ចូលរួមក្នុងសកម្មភាពសប្បាយរីករាយដែលមិនទាក់ទឹងនឹងទំលាប់ចាស់នៃការប្រើថ្នាំញៀន។ សម្រាក។ និយាយជាមួយអ្នកផ្តល់សេវាព្យាបាលគ្រឿងញៀនរបស់អ្នក។

**ឥទ្ធិពលដែលអាចកើតមានដ៏ធ្ងន់ធ្ងរ** - ចំពោះការឈឺក្រពះដ៏ខ្លាំង ការក្អួត ឬជំងឺរាគ សូមទំនាក់ទំនងជាមួយវេជ្ជបណ្ឌិតរបស់អ្នកជាបន្ទាន់។ ហើយត្រូវស្វែងរកជំនួយ បើផលប៉ះពាល់ខាងក្រោមនេះកើតមានឡើង ពីព្រោះវាអាចបញ្ជាក់ថាអ្នកមានបញ្ហាថ្លើមធ្ងន់ធ្ងរ៖

- ទឹកនោមក្រម៉ៅ ឬ ពណ៌ទឹកតែ
- ឈឺក្រពះខ្លាំង
- បត់ជើងធំពណ៌ខ្ចី
- ភ្នែកមានពណ៌លឿង
- ស្បែកពណ៌លឿង

## *ការប្រឹក្សាយោបល់អាចជួយអ្នកបាន។*

ការប្រើថ្នាំ ជាការព្យាបាលមួយផ្នែកសំរាប់ការញៀនអាភៀន។ ចំពោះមនុស្សជាច្រើន ផ្នែកដែលសំខាន់មួយទៀតគឺ ការប្រឹក្សាយោបល់៖ ជាឱកាសឲ្យអ្នកនិយាយជាមួយអ្នកដែលមានជំនាញ អាចធ្វើតាមរយៈនិយាយម្នាក់-ទល់-ម្នាក់ ឬនិយាយជាក្រុម ជាមួយអ្នកផ្សេងទៀតពេលកំពុងព្យាបាល។

តាមរយៈការប្រឹក្សាយោបល់ អ្នកនឹងដឹងពីការនាំឲ្យខំប្រឹង និងឥរិយាបទដែលបណ្ដាលឲ្យអ្នកញៀនថ្នាំ។ អ្នកនឹងដឹងពីវិធីក្នុងការប្រឹងប្រែងជាច្រើនដើម្បីធ្វើឲ្យជីវិតរបស់អ្នកមានសុខភាពល្អប្រសើរឡើង។ អ្នកទទួលបានការគាំទ្រ និងជំនាញនៅកំឡុងពេលធ្វើការជាមួយអ្នកផ្សេងទៀត ដើម្បីគ្រប់គ្រងឲ្យអ្នកសះស្បើយបានយូរអង្វែង។

ការប្រឹក្សាយោបល់អាចផ្ដល់ឲ្យអ្នកនូវការលើកទឹកចិត្ត និងការជំរុញទឹកចិត្តក្នុងការបន្តការព្យាបាល។ វាអាចជួយអ្នកឲ្យដឹងពីវិធីក្នុងការសម្រេចចិត្តដ៏មានសុខភាពល្អ ដោះស្រាយឧបសគ្គ អារម្មណ៍តានតឹង និងបន្តជីវិតរបស់អ្នកទៅមុខទៀត។

នៅក្នុងការប្រឹក្សាជាក្រុម អ្នកអាចទំនាក់ទំនងជាមួយអ្នកផ្សេងទៀតនៅក្នុងការព្យាបាល និងកសាងមិត្តភក្ដិថ្មីដែលមិនប្រើថ្នាំញៀន។ អ្នកថែមទាំងអាចទទួលបានផលប្រយោជន៍នេះពីក្រុមអ្នកគាំទ្រដែរ។ នេះគឺជាការជួបជុំក្រៅផ្លូវការជាក្រុមជាមួយមនុស្សដែលមានឧបសគ្គស្រដៀងគ្នា។

## *ក្រុមគ្រួសារ និងមិត្តភក្ដិក៏សំខាន់ដែរ។*

វាជាការលំបាកណាស់ឲ្យបានជាសះស្បើយដោយម្នាក់ឯង។ ការគាំទ្រពីក្រុមគ្រួសារ និងមិត្តភក្ដិគឺជាការសំខាន់។ ក្ដីស្រឡាញ់ និងការលើកទឹកចិត្តអាចជួយអ្នកឲ្យសម្រេចចិត្តចូលរួមនៅក្នុងការព្យាបាល និងនៅបន្តចូលរួមក្នុងការព្យាបាល។

កម្មវិធីព្យាបាលខ្លះ មានផ្ដល់ការប្រឹក្សាយោបល់ដល់មនុស្សជាទីស្រឡាញ់របស់អ្នក។ គេធ្វើដូច្នេះពីព្រោះការញៀនថ្នាំរបស់អ្នកអាចធ្វើឲ្យមានការឈឺចាប់ និងមានកំហឹង ឬមានអារម្មណ៍ខ្មាស់គេ និងអស់សង្ឃឹម។

ការប្រឹក្សាយោបល់ជាវិធីដែលមានសារៈសំខាន់សម្រាប់ក្រុមគ្រួសារ និងមិត្តភក្ដិ ឲ្យយល់ដឹងបានច្រើនអំពីស្ថានភាពរបស់អ្នក ថាតើត្រូវជួយអ្នកដោយរបៀបណា ហើយថាតើត្រូវដោះស្រាយបញ្ហានៃការញៀនថ្នាំរបស់អ្នកដែលបានបង្ករឡើងដោយរបៀបណា។ វាគឺជាកន្លែងដែលមានសុវត្ថិភាពសម្រាប់ពួកគេក្នុងការបញ្ចេញនូវអារម្មណ៍ និងស្វែងយល់ថា តើមានជំនួយអ្វីខ្លះដែលមានសម្រាប់ជួយដល់ម្នាក់ៗដែលបានរងគ្រោះ។

មានក្រុមអ្នកគាំទ្រសម្រាប់ក្រុមគ្រួសារ និង មិត្តភក្ដិដែរ។ នេះគឺជាកន្លែងដែលមានសុវត្ថិភាពដើម្បីផ្លាស់ប្ដូរព័ត៌មាន និងលើកទឹកចិត្តដល់អ្នកដទៃទៀត ដែលមានមនុស្សជាទីស្រឡាញ់របស់គេដែលកំពុងដោះស្រាយជាមួយនឹងការញៀនថ្នាំ។

> មនុស្សជាច្រើនដែលញៀនថ្នាំអាភៀនអាចវិលត្រលប់មកធម្មតាវិញ គឺជីវិតដែលមានសុខភាពល្អ។ វិធីមួយដែលអាចវិលត្រលប់មកសភាពធម្មតាវិញនេះ គឺការព្យាបាលដោយថ្នាំជំនួយ។ ការប្រើថ្នាំ ការប្រឹក្សាយោបល់ និងការគាំទ្រ៖ រួមគ្នាវាអាចជួយអ្នក ជួយមនុស្សជាទីស្រឡាញ់របស់អ្នក និងមិត្តភក្ដិរបស់អ្នកបាន។

*"មជ្ឈមណ្ឌលព្យាបាលដែលខ្ញុំបានទៅមានការអប់រំជាច្រើនពីការញៀន។ គេនិយាយថាការញៀនដូចជាជំងឺមួយ ហើយមិនមែនជាការបរាជ័យដែលអសីលធម៌ទេ... ខ្ញុំមានបញ្ហាសុខភាព... ហើយវាជាការធូរស្រាលសម្រាប់ខ្ញុំខ្លាំងណាស់ដែលដឹងពីបញ្ហាញៀននេះ និងអាចដឹងថាការសះស្បើយអាចធ្វើបាន។"*

*សីហា*

ព័ត៌មានពិត

# ការញៀន

## តើអ្វីជាការពិត និង អ្វីជាការមិនពិត

**ការញៀនគឺជាជំងឺមួយ។** វាមិនអាចព្យាបាលបានទេ ប៉ុន្តែវាអាចព្យាបាលដោយប្រើថ្នាំ ការប្រឹក្សាយោបល់ និងការគាំទ្រពីក្រុមគ្រួសារ និងមិត្តភក្តិ។ ការញៀនមិនមែនជាសញ្ញាភាពទន់ខ្សោយទេ។ វាមិនមែនជាការពិតទេដែលថា អ្វីៗទាំងអស់ដែលអ្នកត្រូវការដើម្បីផ្តាច់គ្រឿងញៀនគឺ "ត្រូវតែរឹងមាំ"។

**គោលបំណងនៃការប្រើថ្នាំជាជំនួយគឺដើម្បីឲ្យបានជាសះស្បើយពីការញៀន។** វាមិនមែនជាការជំនួសថ្នាំញៀនមួយដោយថ្នាំញៀនមួយប្រភេទផ្សេងទៀតឡើយ។ វាផ្តល់នូវសុវត្ថិភាព កម្រិតនៃការប្រើប្រាស់ថ្នាំមួយដែលអាចគ្រប់គ្រងបាន ដើម្បីឲ្យឈ្នះលើការប្រើប្រាស់អាភៀន។

**អ្នកផ្តល់សេវាព្យាបាលគ្រឿងញៀនត្រូវទទួលការយល់ព្រមពីអ្នកជាមុនសិន (កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ) មុនពេលចែករំលែកព័ត៌មានរបស់អ្នកជាមួយអ្នកផ្សេងទៀត។ មានករណី** លើកលែងពីរចំណុចចំពោះភាពលាក់ការណ៍សម្ងាត់នេះ ៖ (I) បើមើលទៅឃើញថា អ្នកអាចធ្វើឲ្យមានគ្រោះថ្នាក់ចំពោះខ្លួនអ្នក ឬអ្នកដទៃ និង (II) បើអ្នកត្រូវបានបញ្ជាឲ្យចូលរួមព្យាបាលនេះដោយតុលាការ។ ដើម្បីសិក្សាព័ត៌មានបន្ថែមទៀតពីសិទ្ធិនៅក្នុងការរក្សាការសម្ងាត់នេះ សូមនិយាយជាមួយអ្នកផ្តល់សេវាព្យាបាលគ្រឿងញៀនរបស់អ្នក។

**ការជាសះស្បើយគឺអាចធ្វើបាន។** ប៉ុន្តែវាត្រូវការការខិតខំប្រឹងប្រែង។ ក្រោយពេលបញ្ចប់ការព្យាបាល អ្វីៗគឺមិនមែនបានប្រសើរឡើងវិញដោយស្វ័យប្រវត្តិនោះឡើយ។ ការជាសះស្បើយត្រូវការការប្តេជ្ញាចិត្តជារៀងរាល់ថ្ងៃ ក្នុងកំឡុងពេលព្យាបាល និងក្រោយមកទៀត។

# ថ្នាំ BUPRENORPHINE
## តើអ្វីជាការពិត និង អ្វីជាការមិនពិត

**ថ្នាំ buprenorphine ជួយអ្នកឲ្យគិត ហើយដំណើរការមុខងារដូចធម្មតា។** វាជាការស្របច្បាប់ និងត្រូវប្រើប្រាស់ក្រោមការថែទាំរបស់វេជ្ជបណ្ឌិត។ វាមិនដូចជាការប្រើប្រាស់ថ្នាំផ្សេងទៀតដែលនាំឲ្យញៀននោះទេ។

**ថ្នាំ buprenorphine ត្រូវបានផលិតក្នុងលក្ខខណ្ឌដែលមានសុវត្ថិភាព និងលក់ស្របច្បាប់។** គ្មានគ្រោះថ្នាក់ ធ្វើឲ្យខូចកម្រិតណាមួយ ដែលអាចកើតមានឡើងដូចថ្នាំតាមផ្សារងងឹតដែរទេ។ ហើយការប្រឈមមុខនឹងការប្រើហួសកម្រិតចំពោះថ្នាំនេះក៏មានតិចតួចដែរ។

**អ្នកអាចឈប់ប្រើថ្នាំ buprenorphine នៅពេលដែលអ្នកបានស្រួលបួលហើយ។** អ្នកអាចក្លាយខ្លួនត្រូវការថ្នាំ buprenorphine ជាប្រចាំ ដូចថ្នាំផ្សេងៗជាច្រើនទៀតដែរ ពេលប្រើយូរ។ ដោយហេតុផលនេះហើយ បើអ្នកចង់ឈប់ប្រើថ្នាំ buprenorphine អ្នកត្រូវធ្វើការជាមួយអ្នកផ្តល់សេវាព្យាបាលគ្រឿងញៀនដើម្បីកាត់បន្ថយបន្តិចម្តងៗ។ ធ្វើយ៉ាងនេះដើម្បីការពារសញ្ញាកើតពីការឈប់ប្រើអាភៀនកុំឲ្យកើតឡើងវិញ។



## *ក្រុមអ្នកគាំទ្រ និងព័ត៌មាន*

- **តារាងនេះមិនបានពេញលេញទេ។ តារាងរាយឈ្មោះនេះមិនមានន័យថា** Substance Abuse and Mental Health Services Administration (SAMHSA) **ផ្តល់នូវការគាំទ្រដល់អង្គការទាំងនេះទេ។**
- ក្រុមអ្នកគាំទ្រខ្លះមានគោលការណ៍តមតែមួយមុខគត់ ហើយមិនមានចិត្តចង់គាំទ្រការព្យាបាលដោយប្រើថ្នាំជាជំនួយឡើយ។ កម្មវិធីដែលមានចុះនៅទីនេះ គ្មានគោលការណ៍ដូច្នេះឡើយ ប៉ុន្តែការប្រជុំនៃក្រុមនីមួយៗប្រែប្រួល។ អ្នកប្រហែលជាត្រូវសាកល្បងជួបជាមួយក្រុមអ្នកគាំទ្រជាច្រើនក្រុម ដើម្បីស្វែងរកក្រុមណាដែលសមស្របសំរាប់អ្នក។
- កម្មវិធីក្រុមគាំទ្រខ្លះទៀត អនុញ្ញាតឲ្យក្រុមគ្រួសារ និងមិត្តភក្តិចូលរួមក្នុងការប្រជុំ ឬមានកម្មវិធីប្រជុំដោយឡែកសំរាប់ពួកគេ។ សូមស្វែងយល់ពីអង្គការនីមួយៗសម្រាប់ព័ត៌មានលំអិត។
- ក្រុមឧបត្ថម្ភគ្នាទៅវិញទៅមកតាមប្រព័ន្ធអ៊ិនធឺណេតអាចជាជម្រើសដ៏ល្អប្រសើរបំផុតសម្រាប់អ្នក បើគ្មានក្រុមគាំទ្រនៅសហគមន៍របស់អ្នកនោះទេ។ ជម្រើសមួយទៀត គឺទាក់ទង Alcoholics Anonymous (AA, www.aa.org) ដើម្បីស្វែងយល់ ថាតើមានកិច្ចប្រជុំរបស់ AA ក្នុងសហគមន៍របស់អ្នកសម្រាប់មនុស្សដែលកំពុងជាសះស្បើយពីសារធាតុញៀនដទៃទៀតដែរឬទេក្រៅពីគ្រឿងស្រវឹង។

**ធនធានព័ត៌មានសំរាប់អ្នកជំងឺដែលបានជ្រើសរើសជាភាសាអាស៊ី** (Selected Patient Information Resources in Asian Languages)
http://spiral.tufts.edu/index.html

**ប្រដាប់ស្វែងរកសេវាព្យាបាលសុខភាពផ្នែកអាកប្បកិរិយា** (Behavioral Health Treatment Service Locator)
http://findtreatment.samhsa.gov

***សមាគមសុខភាពផ្លូវចិត្តរបស់ជនជាតិអាមេរិកសញ្ជាតិដើមអាស៊ីនិងអ្នកកោះប៉ាស៊ីហ្វិក*** (National Asian American Pacific Islander Mental Health Association)
http://naapimha.org

**សមាគមក្រុមគ្រួសាររបស់ជនជាតិអាមេរិកសញ្ជាតិដើមអាស៊ីនិងអ្នកកោះប៉ាស៊ីហ្វិកប្រឆាំងនឹងការរំលោភបំពាន** (National Asian Pacific American Families Against Substance Abuse)
http://napafasa.org

## *ក្រុមវេជ្ជបណ្ឌិតផ្តល់ថ្នាំប៊្យូព្រេណរ័ហ្វីន (buprenorphine) និងអ្នកចង្អុលបង្ហាញកម្មវិធីព្យាបាល*

1-800-662-HELP(4357) (និយាយភាសាអង់គ្លេស និងអេស្ប៉ាញ)

1-800-487-4889 TDD (សម្រាប់អ្នកពិការត្រចៀក)

http://findtreatment.samhsa.gov

## *កូនសៀវភៅដោយឥតគិតថ្លៃ*

- ការមានអាយុកាន់តែចាស់ទៅ ថ្នាំពេទ្យ និងសុរា
- ការព្យាបាលសុរា និងគ្រឿងញៀន៖ តើវាដំណើរការយ៉ាងដូចម្តេច និងតើវាអាចជួយអ្នកបានយ៉ាងដូចម្តេចខ្លះ - ប័ណ្ណផ្សាយពាណិជ្ជកម្មអតិថិជន ដោយយោងទៅលើ TIP44: ការព្យាបាលការញៀនថ្នាំសំរាប់មនុស្សពេញវ័យដែលស្ថិតនៅក្នុងប្រព័ន្ធយុត្តិធម៌សម្រាប់បទឧក្រិដ្ឋ
- គ្រឿងញៀន សុរា និងមេរោគហ៊ីវ/ជំងឺអេដស៍៖ សៀវភៅមគ្គុទ្ទេសក៏សំរាប់អ្នកប្រើប្រាស់
- សុខភាពល្អខាងខួរក្បាល គឺនៅជាប់ជានិច្ច
- ការជួយខ្លួនឯងអោយជា៖
- សៀវភៅមគ្គុទេសក៏សំរាប់ស្ត្រីដែលជាឡើងវិញក្នុងការលៃលកដោះស្រាយបញ្ហាការរងការធ្វើបាបកាលពីវ័យកុមារ

## *របៀបទទួលបានច្បាប់ចម្លងឥតគិតថ្លៃ*

មានមធ្យោបាយចំនួនបីក្នុងការទទួលបានច្បាប់បោះពុម្ពអ្នកសម្រាប់ប្រើប្រាស់ឥតគិតថ្លៃពីកម្មវិធីដាក់ពាក្យសុំចំណេះដឹង (KAP) ៖

- ស្នើសុំពួកវាពីអ្នកផ្តល់ការព្យាបាលលើការប្រើប្រាស់សារធាតុញៀន។
- ទូរស័ព្ទទៅ SAMHSA តាមលេខ 1-877-SAMHSA-7 (1-877-726-4727) (ភាសាអង់គ្លេស និងអេស្ប៉ាញ)។
- ចូលមើលទំព័រវិបបញ្ជាទិញច្បាប់បោះពុម្ពរបស់ SAMHSA នៅ http://store.samhsa.gov ដើម្បីបញ្ជាទិញ ឬទាញយកច្បាប់បោះពុម្ព។

ច្បាប់បោះពុម្ពអ្នកប្រើប្រាស់ KAP ជាច្រើនអាចរកបានលើបណ្តាញជាភាសាកម្ពុជា (ភាសាខ្មែរ) ចិន កូរ៉េ រុស្ស៊ី អេស្ប៉ាញ និងវៀតណាម  នៅ http://store.samhsa.gov។

*"អ្វីដែលខ្ញុំបានស្វែងយល់នៅក្នុងជីវិតរបស់ខ្ញុំ គឺថាពេលខ្ញុំស្គាល់មនុស្សកាន់តែច្រើន ហើយខ្ញុំប្រាប់គេថាខ្ញុំជាមនុស្សដែលកំពុងបានជាសះស្បើយ... នោះមានមនុស្សកាន់តែច្រើននាក់ឡើង អាចនាំព័ត៌មានទៅប្រាប់មិត្តភក្តិ និងក្រុមគ្រួសារគេថា "ហេ" ខ្ញុំស្គាល់មនុស្សម្នាក់ដែលឈប់ប្រើថ្នាំញៀនតទៅទៀតហើយ ដែលអ្នកនោះធ្លាប់ប្រើពីមុនមក ហើយជីវិតរបស់គេបានប្រសើរឡើង។ ប្រហែលជាអ្នកអាចសាកធ្វើដូចនេះ។"*

*ដាន ភី*


## សេចក្តីថ្លែងអំណរគុណ

ឯកសារបោះពុម្ពផ្សាយនេះ ត្រូវបានត្រៀមរៀបចំសម្រាប់រដ្ឋបាលសេវាសុខភាពផ្លូវចិត្តនិងការប្រើប្រាស់សារធាតុញៀនមិនត្រឹមត្រូវ (Substance Abuse and Mental Health Services Administration, SAMHSA) ដោយកម្មវិធី Knowledge Application Program (KAP) ក្រុមហ៊ុនបណ្តាក់ទុនរកស៊ីរួមគ្នារវាង The CDM Group, Inc ចុះសន្យាលេខ 270-09-0307 and 270-14-0445 ជាមួយSAMHSA ក្រសួងសេវាមនុស្សនិងសុខាភិបាលសហរដ្ឋអាមេរិក(U.S. Department of Health and Human Services, HHS) ។ Christina Currier និង Suzanne Wise បម្រើការជាអ្នកតំណាងរបស់មន្ត្រីជាប់កិច្ចសន្យា(Contracting Officer's Representatives) និង Candi Byrne បម្រើការជាអ្នកសម្របសម្រួលគម្រោងKAP (KAP Project Coordinator) ។



ព័ត៌មានទាំងអស់ដែលមាននៅក្នុងឯកសារនេះ លើកលែងតែព័ត៌មានដែលយកចេញដោយផ្ទាល់ពីប្រភពរក្សាសិទ្ធិគឺសំរាប់សាធារណជន ហើយគេអាចផលិតសារជាថ្មី ឬថតចំលងដោយមិនចាំបាច់មានការអនុញ្ញាត្តិពី SAMHSA/CSAT ឬបណ្ណាអ្នកនិពន្ធ។ ប៉ុន្តែការបោះពុម្ពផ្សាយនេះមិនអាចផលិតឡើងសារជាថ្មី ឬចែកចាយដោយគិតថ្លៃ ដោយគ្មានការអនុញ្ញាតជាក់លាក់ជាលាយលក្ខណ៍អក្សរចេញពី Office of Communication, SAMHSA, HHS នោះទេ។



កូនសៀវភៅនេះអាចត្រូវបានទាញយកពីទំព័រវិបបញ្ជាទិញច្បាប់បោះពុម្ពរបស់ SAMHSA នៅ http://store.samhsa.gov ។

កែសម្រួល និងបកប្រែចេញពីកំណែភាសាអង់គ្លេសនៅឆ្នាំ 2014។

កំណែដើមជាភាសាអង់គ្លេសត្រូវបានបោះពុម្ពនៅឆ្នាំ 2009។

ការបោះពុម្ពផ្សាយរបស់ HHS លេខ (SMA)16-4442KHMER

Substance Abuse and Mental Health Services Administration

SAMHSA

www.samhsa.gov • 1-877-SAMHSA-7 (1-877-726-4727)